**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យនិងដោះស្រាយបញ្ហាដំណើរចេញ ចូលរបស់ពលករខ្មែរតាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតគណៈកម្មការចំពោះកិច្ចត្រួតពិនិត្យនិងដោះស្រាយបញ្ហាដំណើរចេញ ចូលរបស់ពលករខ្មែរនៅតាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** | ឧបនាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឯកឧត្តមសន្តិបណ្ឌិត **គៀត ច័ន្ទថារិទ្ធ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធានប្រចាំការ |
| ៣- ឯកឧត្តម **សំរិទ្ធ ឌី** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- ឯកឧត្តម **សៀក សុជាតិ** | រដ្ឋលេខាធិការក្រសួងការពារជាតិ | អនុប្រធាន |
| ៥- ឯកឧត្តម **ថោង សំអាត** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម **ហេង ចាន់ឌី** | រដ្ឋលេខាធិការក្រសួងអធិការកិច្ច | សមាជិក |
| ៧- អភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែន | | សមាជិក |
| ៨- អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | | សមាជិក |
| ៩- អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | | សមាជិក |

១០- អគ្គស្នងការរងនគរបាលជាតិ ទទួលការងារព្រំដែន សមាជិក

១១- ប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន សមាជិក

១២- ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក សមាជិក

១៣- នាយកទីចាត់ការការងារព្រំដែននៃអគ្គបញ្ជាការដ្ឋាន សមាជិក។

**ប្រការ២ .–**

គណៈកម្មការចំពោះកិច្ចមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- តាមដាននិងត្រួតពិនិត្យការអនុវត្តវិធានការនានាដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល ដើម្បីលុបបំបាត់ភាពមិនប្រក្រតីនិងបាតុភាពផ្សេងៗ ក៏ដូចជាបញ្ហាប្រឈមនានាចំពោះពលករខ្មែរក្នុងការចេញ ចូល និងឆ្លងកាត់ព្រំដែន
- ជំរុញដល់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅតាមព្រំដែន ដើម្បីជួយសម្រួលដំណើរចេញ ចូលរបស់ពលករខ្មែរឱ្យបានត្រឹមត្រូវ
- ទទួលនិងដោះស្រាយបណ្តឹងតវ៉ានានារបស់ពលករខ្មែរពាក់ព័ន្ធនឹងដំណើរឆ្លងកាត់ព្រំដែន
- សិក្សាស្រាវជ្រាវលើប្រភពបញ្ហាឬភាពមិនប្រក្រតីនានា ដែលបង្កការរំខានដល់ដំណើរចេញ ចូល ឬប៉ះពាល់ដល់ផលប្រយោជន៍របស់ពលករខ្មែរតាមព្រំដែន
- រៀបចំឱ្យមានប្រព័ន្ធឆ្លើយតបបន្ទាន់ ដើម្បីសម្រួលឱ្យពលករអាចទំនាក់ទំនងនិងរាយការណ៍ភាពមិនប្រក្រតី
- ធ្វើការត្រួតពិនិត្យ តាមដានការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីមានបណ្តឹងមិនសុខចិត្តពីពលករ
- ចុះពិនិត្យ សិក្សា និងវាយតម្លៃអំពីស្ថានភាពនៃការយកកម្រៃក្រៅផ្លូវការសម្រាប់ការធ្វើដំណើរចេញចូលនៅច្រកទ្វារព្រំដែន
- ដាក់ចេញវិធានការ ចុះប្រតិបត្តិការ ឬចេញសេចក្តីណែនាំ ដើម្បីលុបបំបាត់ការយកកម្រៃក្រៅផ្លូវការសម្រាប់ការធ្វើដំណើរចេញចូលនៅច្រកទ្វារព្រំដែន សំដៅសម្រួលដល់ការធ្វើដំណើរចេញចូលរបស់ពលករនៅតាមព្រំដែន
- ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលអំពីវឌ្ឍនភាពការងារ និងបញ្ហាប្រឈមទាក់ទងនឹងការងារលុបបំបាត់ការយកកម្រៃក្រៅផ្លូវការសម្រាប់ការធ្វើដំណើរចេញចូលនៅច្រកទ្វារព្រំដែន
- អនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ពីប្រមុខរាជរដ្ឋាភិបាល។

**ប្រការ៣ .–**

អនុប្រធាននិងសមាជិកនៃគណៈកម្មការចំពោះកិច្ច ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការចំពោះកិច្ច។ ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានដែលបានទទួលសិទ្ធិពីប្រធានអាចកោះប្រជុំនិងដឹកនាំកិច្ចប្រជុំជំនួសបាន។

អនុប្រធាននិងសមាជិកគណៈកម្មការចំពោះកិច្ច ត្រូវបំពេញការងារតាមការបែងចែកភារកិច្ចដែលកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការចំពោះកិច្ច ។

ប្រធានគណៈកម្មការចំពោះកិច្ច អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានីខេត្ត និងអាជ្ញាធរដែលមានការពាក់ព័ន្ធ ចូលរួមក្នុងកិច្ចប្រជុំឬប្រតិបត្តិការការងាររបស់ខ្លួនតាមការចាំបាច់។

គណៈកម្មការចំពោះកិច្ច អាចប្រើប្រាស់មន្ត្រីជំនាញឬយន្តការជំនាញរបស់ក្រសួងស្ថាប័ន និងអាជ្ញាធរដែនដីដែលមានតំណាងនៅក្នុងគណៈកម្មការ ដើម្បីជាជំនួយដល់ការបំពេញការងាររបស់ខ្លួនតាមការចាំបាច់។

**ប្រការ៤ .-**

គណៈកម្មការចំពោះកិច្ចអាចបង្កើតក្រុមការងារមួយចំនួនតាមការចាំបាច់ ដើម្បីអនុវត្តការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដោយប្រើប្រាស់មន្ត្រីជំនាញឬយន្តការជំនាញរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលមានតំណាងនៅក្នុងគណៈកម្មការ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងាររបស់គណៈកម្មការចំពោះកិច្ចត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការចំពោះកិច្ច។

**ប្រការ៥ .-**

គណៈកម្មការចំពោះកិច្ចមានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីដំណើរការការងាររបស់ខ្លួន។

ថវិកាចំណាយ មធ្យោបាយ និងសម្ភារៈបរិក្ខាសម្រាប់ការបំពេញបេសកកម្មរបស់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការចំពោះកិច្ច ជាបន្ទុករបស់ក្រសួង ស្ថាប័នសាមី។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តជាប់ព្រំដែន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហ ១០រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ